# សិលាចារឹកប្រាសាទសំពេង

ប្រាសាទសំពេង មានទីតាំងស្ថិតនៅភូមិដូនស្ងួន ឃុំស្រយង់ ស្រុកគូលែន ខេត្តព្រះវិហារ។ ប្រាសាទនេះកសាងឡើងនៅលើទួលមួយ បែរមុខទៅទិសខាងកើត មានតួប៉មចំនួនមួយ ជាប្រភេទប្រាសាទខ្នាតតូច សង់អំពីថ្មបាយក្រៀម និងមេទ្វារសាងអំពីថ្មភក់។ ប្រាសាទសំពេង ប្រហែលជាស្ថាបត្យកម្មសាសនាឧទ្ទិសដល់ព្រហ្មញ្ញសាសនានៅក្នុងស.វ.ទី១០។ ប៉ុន្តែសិលាចារឹកដែលចារឹកនៅលើមេទ្វាររបស់ប្រាសាទទាំងសងខាង ពុំមែនចារឹកឡើងនៅស.វ.ទី១០នោះទេ។ សិលាចារឹកនេះ មានលក្ខណៈតួអក្សរដែលអាចសម្គាល់បានថា "អក្សរខ្មែរសម័យមុនអង្គរ" នៅរវាងស.វ.ទី៧ ឬទី៨ ពោល គឺអាចមានន័យថា នៅពេលគេកសាងប្រាសាទថ្មីនៅស.វ.ទី១០ គេបានយកមេទ្វាររបស់ប្រាសាទចាស់ណាមួយនៅស.វ.ទី៧ មកធ្វើជាមេទ្វាររបស់ប្រាសាទថ្មីនៅស.វ.ទី១០ ដោយផ្នែកខ្លះរបស់ថ្មមេទ្វារគេបានកាត់ច្រៀកជាថ្មីឱ្យត្រូវគ្នាជាមួយប្រាសាទផងដែរ។ ម្យ៉ាងវិញទៀត គេថែមទាំងបានកោសលុបសិលាចារឹកចាស់នោះទៀតផង។

សិលាចារឹកប្រាសាទសំពេង ចារឹកជាភាសាខ្មែរបុរាណនៅលើមេទ្វាររបស់ប្រាសាទ។ នៅមេទ្វារខាងជើង មានសិលាចារឹកតែ ២ បន្ទាត់ប៉ុណ្ណោះ ប៉ុន្តែនៅមេទ្វារខាងត្បូងមានសិលាចារឹកចំនួន ១៤ បន្ទាត់។ ថ្វីត្បិតតែសិលាចារឹក ធ្លាប់មានការកោសលុបយ៉ាងណាក៏ដោយ ក៏យើងអាចព្យាយាមផ្គាមអក្សរ និងអានអត្ថន័យរបស់សិលាចារឹកបានដែរ។ អត្ថន័យជារួមរបស់សិលាចារឹកប្រាសាទសំពេង គឺរៀបរាប់អំពីអំណោយរបស់ឥស្សរជន (អភិជន) មួយចំនួន ដែលម្ចាស់អំណោយទាំងអស់សុទ្ធតែមានគោរម្យងារថា "បោញ" (គោរម្យងារមន្ត្រីជាន់ខ្ពស់នៅសម័យមុនអង្គរ) រួមមានបោញឦស្វរ បោញកាស បោញដោង។ អំណោយរបស់បោញទាំងនេះ ថ្វាយដល់ព្រះឥស្វរក្នុងទម្រង់ព្រះនាមថា "**ព្រះកម្រតាងអញ ស្រីកទ្រេស្វរ**"។ អំណោយមានដូចជា ដីស្រែ អ្នកបម្រើស្រី អ្នកបម្រើប្រុស និងក្មេងតូចៗ ដែលមានសម្គាល់ដោយពាក្យថា កុ (ស្ត្រី) និង វា (បុរស) កោន (កូន)។

គួរកត់សម្គាល់ថា ព្រះឥស្វរ ក្នុងទម្រង់ព្រះនាមថា "ស្រីកទ្រេស្វរ" នេះ យើងធ្លាប់ឃើញមាននៅក្នុងសិលាចារឹកជាច្រើននៅសម័យមុនអង្គរ (ស.វ.ទី៧-៨) ដូចជា សិលាចារឹកប្រាសាទភ្នំហាន់ជ័យ K.81 សិលាចារឹកគោកប្រាសាទ K.158 សិលាចារឹកប្រាសាទអំពិលរលំ K.162 សិលាចារឹក

អត្ថបទដោយ៖ កំ វណ្ណាវ៉ា

គោកឫស្សី K.175 ។ល។ ពាក្យថា "កម្រេគ្ងរ" មកពីពាក្យថា "កម្រេ" និង "ព្ញៀគ្ងរ" សំដៅដល់ព្រះឥសូរ ឬ ព្រះស្វាមីរបស់ព្រះនាងកម្រោ ហើយព្រះនាងកម្រោ គឺសំដៅដល់ "ព្រះនាងទុគ៌ា" ក្នុងទម្រង់មួយរបស់ទេវី "ឧមា" ដែលជាព្រះមហេសីព្រះឥសូរ។ ជួនកាលមានសំណេរសំស្ក្រឹតថា ឧមេគ ដូច្នេះក៏មាន ដែលសំដៅដល់ ទេពឥសូរស្វាមីព្រះនាងឧមា។ "**ព្រះកម្រតាងអញ ស្រីកម្រេស្វរ**" ទំនងជារូបភាពជាសិវលិង្គ ព្រោះនៅសម័យមុនអង្គរគេមិននិយមធ្វើរូបភាពព្រះសិវជាបដិមាករឡើយ។

## អត្ថបទពាក្យចារឹក

### មេទ្វារខាងត្បូង

១. .....និ អំនោយ៑ វ្រះកម្រតាង៑ អញ គ្រឹកម្រេគ្ងរ
២. ..ស.........................
៣. ... ទ....................................
៤. ......កុ កន១ កោន្ទុ១
៥. ...កោន្ទុ៣ កុ អក្តមត៑១ កោន្ទុ២
៦. ...នុ អញ៑ ទោង គុ ..មត៑ អញ៑ ផោង្គុ
៧. ....វ្រះកម្រតាង៑ អញ៑ កម្រេគ្ងរ
៨. ..........វ្រះ ក្បាង៑ អន្ទគោ កោន្ទុ១
៩. .......[អ]ម្នោយ៑ ប៉ោញ៑ ព្ញៀគ្ងរ គិ ស្រេ អំនោយ៑ ប៉ោញ៑
១០. ....ប៉ោញ៑ ភាស៑ ផោង្គុ តេល្ងយ៑ ត វ្រះកម្រតាង៑
១១. ...........អំនោយ៑ ប៉ោញ៑ ដោង៑ ......ង៑
១២. ..........ផោង្គិ () ត វេរ៑ អាចាយ៌្យ គាន្ត ស្រេ
១៣. ............................ញ្ជ ត វ្រះ
១៤. វ្រះ

### មេទ្វារខាងជើង

១. .....................
២. ន្តិ កន្ទិន១ ..............

អត្ថបទដោយ៖ កំ វណ្ណាក់

៣.　វា ក ....................

ជារួមមក ថ្វីត្បិតតែសិលាចារឹកប្រាសាទសំរោង ដែលស្ថិតនៅក្នុងខេត្តព្រះវិហារ ធ្លាប់មានការកោសលុបអក្សររួចមកហើយក្តី ក៏ផ្នែកជាច្រើនដែលនៅអាចមើលឃើញបានផ្តល់ព័ត៌មានដល់អ្នកសិក្សាឱ្យដឹងថាគេចង់និយាយរៀបរាប់អំពីអ្វីដែរ។ សិលាចារឹកនេះទំនងជាអក្សរនៅរវាង ស.វ.ទី៧ ឬទី៨ ដែលរៀបរាប់អំពីតង្វាយរបស់តស្សរជនមួយចំនួនថ្វាយចំពោះព្រះសិវក្នុងព្រះនាមថា "**ព្រះកម្រតាងអញ ស្រីកទ្រេស្វរ**"។



រូបលេខ១៖ ប្រាសាទសំរោង ស្រុកគូលែន ខេត្តព្រះវិហារ

អត្ថបទដោយ៖ កំ វណ្ណាក់



រូបលេខ២៖ ប្រាសាទសំពោង ស្រុកគូលែន ខេត្តព្រះវិហារ

អត្ថបទដោយ៖ កំ វណ្ណាក់



រូបលេខ៣៖ សកម្មភាពផ្តិតសិលាចារឹកប្រាសាទសំពៅង ខេត្តព្រះវិហារ

អត្ថបទដោយ៖ កំ វណ្ណារ៉ា



រូបលេខ៤៖ ក្រដាសផ្តាមសិលាចារឹកប្រាសាទសំពេង មេទ្វារខាងត្បូង (ផ្តិតដោយ៖ កំ វណ្ណាវ៉ា)

អត្ថបទដោយ៖ កំ វណ្ណាវ៉ា



រូបលេខ២៩៖ ការផ្តិតសិលាចារឹកប្រាសាទសំពេង មេទ្វារខាងជើង (ផ្តិតដោយ៖ កំ វណ្ណារ៉ា)

អត្ថបទដោយ៖ កំ វណ្ណារ៉ា